ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ០០៦ សណន

# សេចក្តីណែនាំ
# ស្តីពី
# ការពង្រឹងការអនុវត្តវិធានការនានា ដើម្បីបង្ការទប់ស្កាត់ ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ ក្នុងព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ដល់ថ្នាក់ដឹកនាំ មន្ត្រីនគរបាលជាតិ មន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ នៃក្រសួងមហាផ្ទៃ

ដោយពិនិត្យឃើញថា ចំនួនអ្នកឆ្លងជំងឺកូវីដ១៩ ក្នុងព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ មានការកើនឡើងជាបន្តបន្ទាប់ ដែលមកទល់ពេលនេះ បានធ្វើឱ្យប្រជាពលរដ្ឋចំនួន ០៥ រូប ស្លាប់បាត់បង់ជីវិត ក្នុងនោះ ក៏មានមន្ត្រីនគរបាលជាតិចំនួន ០២ រូប ផងនោះ ក្រសួងមហាផ្ទៃ សូមធ្វើការក្រើនរំលឹកដល់ថ្នាក់ដឹកនាំ មន្ត្រីនគរបាលជាតិ មន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ គ្រប់លំដាប់ថ្នាក់ បន្តពង្រឹងអនុវត្តវិធានការនានារបស់រាជរដ្ឋាភិបាល ក្រសួងសុខាភិបាល និងការណែនាំជាបន្តបន្ទាប់របស់ក្រសួងមហាផ្ទៃ ក្នុងការបង្ការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ ជាពិសេសត្រូវបន្តយកចិត្តទុកដាក់អនុវត្តនូវវិធានការចាំបាច់នានា ដូចខាងក្រោម៖

១. ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការ ៣ការពារ គឺ ពាក់ម៉ាស, លាងដៃ, រក្សាគម្លាតសុវត្ថិភាពសង្គម និងគម្លាតសុវត្ថិភាពបុគ្គល ចាប់ពី ១,៥០ម៉ែត្រឡើងទៅ ឱ្យបានគ្រប់ៗគ្នា នៅគ្រប់ទីកន្លែង និងត្រូវអនុវត្តឱ្យបានគ្រប់គ្នា និង ៣កុំ គឺ កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល និងប្រើម៉ាស៊ីនត្រជាក់ច្រើនពេក រកកន្លែងមានខ្យល់ចេញចូល, កុំទៅកន្លែងមានមនុស្សច្រើនកុះករ និងកុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា កុំកៀកស្មាគ្នា កុំឱបថើបគ្នា។

២. គោរពអនុវត្តឱ្យបានម៉ឺងម៉ាត់នូវច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត និងអនុក្រឹត្យស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ផ្សេងទៀត ព្រមទាំងបន្តផ្សព្វផ្សាយខ្លឹមសារសំខាន់ៗនៃលិខិតបទដ្ឋានគតិយុត្តទាំងពីរនេះ ដល់កងកម្លាំងនគរបាលជាតិ មន្ត្រីរាជការស៊ីវិល មន្ត្រីពន្ធនាគារ ចំណុះក្រសួងមហាផ្ទៃ និងក្រុមគ្រួសារ សំដៅរួមគ្នាគោរពអនុវត្តឱ្យបានសកម្មផុលផុស និងមានប្រសិទ្ធភាព។

៣. បន្តអនុវត្តវិធានការកាត់បន្ថយមន្ត្រីមកបំពេញការងារ និងវិធានការនានា ដែលបានកំណត់ក្នុងសេចក្តីណែនាំលេខ ០០២ សណន ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ ឱ្យបានខ្ជាប់ខ្ជួនម៉ឺងម៉ាត់បំផុត រហូតមានការណែនាំជាថ្មីរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ឬការជូនដំណឹងរបស់ក្រសួងមហាផ្ទៃ។

៤. សម្រាប់ថ្នាក់ដឹកនាំ មន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាលជាតិ និងមន្ត្រីពន្ធនាគារ ដែលមិនត្រូវបានចាត់ឱ្យមកប្រចាំការនៅតាមអង្គភាពនីមួយៗ ត្រូវបន្តបំពេញការងារពីចម្ងាយតាមរយៈអនឡាញ (Online) ហើយមិនត្រូវធ្វើដំណើរចេញក្រៅផ្ទះបើមិនចាំបាច់ និងត្រូវណែនាំដល់ក្រុមគ្រួសាររបស់ខ្លួនឱ្យអនុវត្តនូវវិធានការការពារជំងឺកូវីដ១៩ ដើម្បីរួមគ្នាបង្ការទប់ស្កាត់ការឆ្លងជំងឺនេះ ក្នុងក្រុមគ្រួសាររបស់ខ្លួន និងនៅក្នុងសហគមន៍។

៥. អគ្គស្នងការដ្ឋាននគរបាលជាតិ ត្រូវធ្វើការណែនាំដល់អង្គភាពកងកម្លាំងនគរបាលទាំងអស់ ដែលត្រូវបំពេញភារកិច្ចរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ជាពិសេសនៅតាមអង្គភាពដែលត្រូវប្រមូលផ្តុំកម្លាំង ឱ្យបង្កើនការយកចិត្តទុកដាក់ខ្ពស់ក្នុងការពង្រឹងការអនុវត្តវិធានការសុខាភិបាលនានា ដើម្បីបង្ការទប់ស្កាត់ការចម្លងជំងឺកូវីដ១៩ ដល់មន្ត្រីនគរបាលជាតិ ទាំងក្នុងពេលបំពេញការងារ និងក្នុងអង្គភាពនីមួយៗ ក៏ដូចជាក្នុងក្រុមគ្រួសារ។

៦. អគ្គនាយកដ្ឋានពន្ធនាគារ ត្រូវបង្កើនការយកចិត្តទុកដាក់ខ្ពស់ក្នុងការពង្រឹងការអនុវត្តវិធានការសុខាភិបាលនានា ការថែរក្សាសុខភាព និងអនាម័យចំពោះជនជាប់ឃុំ ដើម្បីបង្ការទប់ស្កាត់ការចម្លងជំងឺកូវីដ១៩ ដល់មន្ត្រីអនុរក្សពន្ធនាគារ និងជនជាប់ឃុំទាំងអស់ នៅតាមពន្ធនាគារ និងមណ្ឌលអប់រំកែប្រែនានាទូទាំងប្រទេស។

ថ្នាក់ដឹកនាំ មន្ត្រីនគរបាលជាតិ មន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ គ្រប់លំដាប់ថ្នាក់ ត្រូវអនុវត្តសេចក្តីណែនាំនេះឱ្យបានម៉ឺងម៉ាត់ និងមានប្រសិទ្ធភាព ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

ថ្ងៃសុក្រ ១០កើត ខែ ជេស្ឋ ឆ្នាំឆ្លូវ ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

<u>ចម្លងជូន៖</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសុខាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- គ្រប់អគ្គនាយកដ្ឋាន និងអង្គភាពចំណុះក្រសួងមហាផ្ទៃ
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ